# បទអប់រំទី

## ស្ដីអំពី: "អត្ថន័យនៃបុណ្យមាឃបូជា"




កម្ពុជរដ្ឋជាប្រទេសមួយ ដែលធ្លាប់ទទួលបាន នូវកិត្តិសព្ទដ៏ល្បីល្បាញខាង វប្បធម៌ អារ្យធម៌ សីលធម៌ ស្ថាបត្យកម្មនិងសន្តិភាពនយោបាយ ។



មិនមែនជាភាពចៃដន្យទេ ដោយមានអំណោយផល ខាងវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីខ្មែរជាម្ចាស់ស្រុកផង បូកផ្សំជាមួយនឹងវប្បធម៌សាសនាធំៗពីរគឺ ពុទ្ធសាសនា និងសាសនាព្រាហ្មណ៍ ដែលហូរចេញពីប្រទេសឥណ្ឌាផង និងរួមទាំងថ្នាក់ដឹកនាំក៏គោរព ហើយយកគោលការណ៍ មកជានីតិរបៀបដឹកនាំប្រទេសផង ទើបធ្វើឲ្យចរន្តនៃវប្បធម៌ទាំងនេះរលាយចូលគ្នាជាល្បាយតែមួយ នៃអារ្យធម៌ប្រទេស។



ហេតុនេះ ទើបយើងសង្កេតឃើញមានស្ថាបត្យកម្ម ប្រាង្គប្រាសាទ របៀបដឹកនាំ ពិធីប្រពៃណី ពិធីសាសនា និងមង្គលផ្សេងៗនៅតែរក្សាបានទូវ អត្តសញ្ញាណ នៃវប្បធម៌ទាំងនោះមកទល់នឹង បច្ចុប្បន្ននេះ។

បណ្ដាពិធីផ្សេងៗ ទាំងប្រពៃណីទាំងសាសនា និងទាំងមង្គល សុទ្ធតែមានសម្ព័ន្ធភាពគឺការផ្សារ ភ្ជាប់ទំនាក់ទំនងគ្នាជាដរាប ទោះបុព្វសិទ្ធិនៃពិធី នោះជាខេមរវប្បធម៌ ក៏ត្រូវមានសារជាតិនៃពិធី

សាសនារួមផ្សំជាកម្លាំងដែរ គឺមិនអាចអត់មានមួយណាបានឡើយ នេះជាទម្លាប់ក្នុងប្រទេសខ្មែរយើង ។ ហេតុដូច្នេះ ទើបពិធីបុណ្យនិងពិធីមង្គលទាំងឡាយ ដូចជាពិធីរៀបអាពាហ៍ពិពាហ៍ និងពិធីបុណ្យមាឃ-បូជានេះជាដើម ។

ទាក់ទងទៅនឹងពិធីបុណ្យមាឃបូជានេះ ខ្ញុំនឹងលើកយកប្រវត្តិពីបុរាណកាល និងការអធិប្បាយផ្ទាល់របស់ខ្ញុំខ្លះៗ ជូនជនានុជនដូចតទៅ ៖

មាឃបូជា គឺជាបុណ្យនៃសង្គមជាតិ និងពុទ្ធ-សាសនា ដែលស្ថិតនៅក្នុងចំណោមបុណ្យធំៗទាំង៤ គឺ វិសាខបូជា មាឃបូជា អាសាឍបូជា(បុណ្យចូលព្រះវស្សា) និងបុណ្យបវារណាកម្ម (ការចេញព្រះវស្សា) ។ ប៉ុន្តែពុំមានកាលបរិច្ឆេទបញ្ជាក់ថាបុណ្យនេះ កើតឡើងក្នុងរជ្ជកាលណាទេ ។

បើយោងតាម សៀវភៅព្រះរាជពិធីទ្វាទសមាសភាគទី២ និយាយតែពីប្រវត្តិនៃបុណ្យវិសាខបូជា ដែលកើតមានក្នុងរជ្ជកាលនៃព្រះបាទ **ហរិរក្សរាមាធិបតី** (ព្រះបាទអង្គឌួង) ដែលទ្រង់គង់ប្រថាប់ក្នុងក្រុងឧត្តុង្គមានជ័យក្នុងព.ស.២៣៩៧គ.ស. ១៩៨៥ ។

បើតាមសេចក្តីនេះ អាចឲ្យសន្និដ្ឋានបានថា បុណ្យមាឃបូជា ក៏ប្រហែលជាត្រូវបានគេផ្តើមធ្វើឡើងក្នុងពុទ្ធសករាជនោះផងដែរ ពីព្រោះបុណ្យទាំងពីរនេះ គឺជាបុណ្យរំឭកថ្ងៃខួបនៃមហាកិលក្ខិតកាលធំៗ របស់ព្រះសមណគោតមដែលជាសាស្តានៃមនុស្សនិងទេវតា ។

ចូលមកដល់ឱកាសនេះ បណ្តាខេមរជនមានទាំងព្រះសង្ឃ ឧបាសក ឧបាសិកា ជូនជី តាជី យុវជន យុវតី កុមារ កុមារី ដែលជាពុទ្ធសាសនិក

ពុទ្ធសាសនិកា ប្រមាណ៩០ភាគរយនៃប្រជាជនសរុប គឺស្មើនឹងប្រជាពលរដ្ឋ១៣លាន៥សែននាក់ លើប្រជាពលរដ្ឋ១៥លាននាក់ បានចូលរួមប្រារព្ធនូវបុញ្ញកម្មនេះ ហើយទាំងបានរៀបចំចាត់ចែង តុបតែងត្រៀមទុកជា ស្រេចស្រាប់នូវទង់ជាតិ ទង់សាសនា ព្រះបដ ព្រះពុទ្ធរូប ព្រះសារីរិកធាតុ រួមទាំងគ្រឿងឧបោសនោបករណ៍ គ្រឿងប្រដាប់ប្រដាបូជា គ្រឿងប្រទីបផ្កាលា គ្រឿងទ្រោលបំភ្លឺទៀនធូបផ្កាភ្ញី គ្រឿងគន្ធពិដោរក្រអូបឈ្ងុយឈ្ងប់ផ្សេងៗ យ៉ាងសម្រិតសម្រាំងល្អឥតខ្ចោះ ទៅតាមទម្រង់បរិបទវប្បធម៌ អារ្យធម៌ ប្រពៃណី និងទំនៀមទម្លាប់នៃប្រទេសរៀងៗខ្លួន ។ ព្រោះហេតុនោះ ទើបយើងក្រឡេកឃើញនូវសកម្មភាព និងកាយវិការដ៏រស់រវើកនៃប្រជាពុទ្ធបរិស័ទ មានចំនួនយ៉ាងច្រើនក្នុងប្រទេសដ៏តូចច្រឡឹងមួយនេះ ដូចជានៅក្នុង

ទីវត្តអារាមត្រង់ខ្លោងទ្វារ ព្រះវិហារ ទីលានព្រះ-ចេតិយ ព្រះស្រីមហាពោធិព្រឹក្ស ត្រូវបានតុបតែងរចនាយ៉ាងល្អល្អះ ដោយគ្រឿងប្រទីបផ្កាលា ភ្លើងពណ៌លម្អទ្រោលបំភ្លឺ និងផ្កាភ្ញីផ្កាកម្រងក្រអូបសាយសព្វ, មានភ្លេងពិណពាទ្យចាក់ប្រគំលាំងណុងពីពោះរណ្ដំរងំ, មានសទ្ទបទនមស្ការថ្វាយបង្គំព្រះ-រតនត្រ័យ សូធ្យប្រជេញបណ្ដាក់ទម្ងាក់តៗគ្នាទ្រហឹងមានសំឡេងព្រះសង្ឃចម្រើនព្រះបរិត្ត បញ្ចៀស-កយន្តរាយ ឮលាន់ខ្ទរខ្ទាររំពងដ៏យ៉ាងស្រុះស្រួលរំជួលសោតា, លុះព្រះទិនករជ្រេទេរទាបស្រយុតចុះទៅ ការសម្ដែងព្រះធម៌ទាក់ទងនឹងបុណ្យមាឃបូជាបទឧគ្ឃោសនសព្ទ បទប្រកាសជយឃោស បទសូធ្យមានបែបផ្សេងៗទាក់ទងទៅនឹងអតីតប្បវត្តិ របស់ព្រះពុទ្ធនិងសាវកសាវិកា បានលេចឮគឹកកងរំពង

ខូវខ្វាយគ្រប់វត្តអារាមទាំងអស់ នៃព្រះរាជាណាចក្រកម្ពុជា ។



មានលក្ខណសម្បត្តិ៣យ៉ាង ដែលពុទ្ធសាសនិកនាំគ្នាប្រារព្ធបុណ្យមាឃបូជានេះឡើង ដែលយើងត្រូវតែចេះដឹងជាចាំបាច់គឺ ៖

ក.ចតុរង្គសន្និបាតប្រកបដោយអង្គ៤

ខ.ថ្ងៃព្រះពុទ្ធទ្រង់សម្ដែងឱវាទប្បាតិមោក្ខ

គ.ថ្ងៃដែលព្រះពុទ្ធទ្រង់ដាក់អាយុសង្ខារ

ថ្ងៃមាឃបុណ្ណមី ជាពេលប្រកបទៅដោយនក្ខត្តឫក្សអស្ចារ្យផងដែរ ដែលមានព្រឹត្តិការណ៍សំខាន់ៗ៣ដូចបាននិយាយខាងលើកើតឡើង ។ ដំណើរដើមទងនៃព្រឹត្តិការណ៍ទាំងនេះ គឺជាសម័យមួយព្រះសម្មាសម្ពុទ្ធជាម្ចាស់ស្តេចគង់នៅ ក្នុងគុហា (រូងភ្នំ) **ឈ្មោះសូករខតា** នាភ្នំគិជ្ឈកូដ (ភ្នំមានកំពូលដូចជាសត្វត្មាត) ជិតក្រុងរាជគ្រឹះ ដើម្បីសម្តែងទីឃនខសូត្រ ប្រោសទីឃនខបរិព្វាជក ។ ក៏ឯខ្លឹមសារនៃព្រះធម៌ក្នុងទីឃនខសូត្រនោះ គឺទ្រង់សម្តែងទាក់ទងទៅនឹង កំណើនៃមហាភូតរូបបួនយ៉ាង (ទឹក, ដី,ភ្លើង,ខ្យល់) ដែលចម្រើនឡើងដោយសារបាយទឹក និងនំចំណីជាដើម, សភាវៈនៃមហាភូតរូបទាំងនោះ មិនទៀងទាត់តែងព្រាត់មិនថេរ ជាទុក្ខជារោគ ជាបូស ជាកូនសរ ជារបស់គួរខ្ពើម, ការសោយអារម្មណ៍ ជាសុខជាទុក្ខនិងមិនមែនជា

សុខមិនមែនជាទុក្ខ និងនិព្វានគឺការនឿយណាយក្នុងរូប បុគ្គល សត្វនិងសង្ខារ ដែលជាហេតុដើរទៅកាន់គន្លងនៃវិមុត្តិ ខណៈដែលបុគ្គលយល់ព្រះធម៌ច្បាស់ ។ គាប់ជួនវេលានោះឯង ព្រះធម្មសេនាបតីកុង្សីយ៍ធម៌ គង់ស្ថិតនៅខាងព្រះប្រឹស្ឋាង្គ (ខាងក្រោយខ្នង) នៃព្រះបក់ផ្លិតថ្វាយព្រះមានព្រះភាគបានពិចារណាក្រសែព្រះធម៌បានសម្រេច ជាព្រះ-អរហន្តជាទីបំផុតនៃសាវកបារមីញាណ និងបញ្ញា ១៦ ។ ចំណែកឯទីឃនខៈក៏បានសម្រេចសោតាបត្តិ-ផល ។ នាកាលព្រះអាទិត្យហៀបនឹងអស្តង្គត ព្រះពុទ្ធស្តេចយាងចុះពីកំពូលភ្នំគិជ្ឈកូដ ហើយយាងទៅកាន់វិហារវេឡុវ័ន ហើយទ្រង់ធ្វើសាវកសន្និ-បាតមានអង្គ៤ ។

## ក.ព្រឹត្តិការណ៍ទី១ ចតុរង្គសន្និបាតមានអង្គ៤



១. ព្រះចន្ទរាងខ្ពើត ខែមាឃពេញវង់ល្អ ហើយទ្រង់ធ្វើវិសុទ្ធបោសថ,

២. នៅថ្ងៃនោះ មានព្រះភិក្ខុសង្ឃចំនួន ១២៥០អង្គ មិនធ្វើការណាត់ជួបទេ ក៏និមន្តមកកាន់សម្នាក់ព្រះសាស្តាព្រមគ្នាក្នុងថ្ងៃនោះ,

៣.ព្រះភិក្ខុសង្ឃទាំងអម្បាលនោះ សុទ្ធតែជាឯហិភិក្ខុទាំងអស់,

៤.ព្រះភិក្ខុសង្ឃទាំងអស់នោះ សុទ្ធតែជាព្រះ-

អរហន្តខីណាស្រពមិនបុថុជ្ជនឡើយ ។ ចតុរង្គសន្និ-បាតឬសាវកសន្និបាតបែបនេះ មានតែម្ដងប៉ុណ្ណោះក្នុងសម័យពុទ្ធកាល មិនកើតមានឡើងច្រើនដងបានទេ ។

## ព្រឹត្តិការណ៍ទី២

## ខ.ថ្ងៃទ្រង់ប្រកាសសម្ដែងឱវាទបា្បតិមោក្ខ



ឱវាទបា្បតិមោក្ខ ជាកម្រងដំបូន្មានដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែង ដើម្បីដឹកនាំសត្វទាំងអស់ឲ្យរួចទុក្ខ ។ បុគ្គលណាមួយក្នុងលោកនេះ បានគោ

វពតាមឱវាទ ដែលទ្រង់ត្រាស់សម្តែងហើយ ទោះបីមិនទាន់បានចាក់ធ្លុះនូវគុណធម៌ ថ្នាក់ខ្ពស់ក៏ដោយ ក៏គង់ទទួលបានកម្រៃសេចក្តីសុខសេចក្តីចម្រើនក្នុងពេលបច្ចុប្បន្ននេះដែរ ។ អត្ថរសដ៏ពិសិដ្ឋឥតអ្វីប្រៀបនៃក្រសែព្រះពុទ្ធោវាទ ដែលក្រមដើមឬវដ្តជម្មនុញ្ញដើមរបស់ពិភពលោកមានជាអាទិ៍គឺៈ

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។**

(សម្រាយសេចក្តីគាថាទី១៥) **អករណំ** វីការមិនធ្វើមិនប្រព្រឹត្តផ្ទាល់ខ្លួន ឬការមិនញ៉ាំងគេឲ្យធ្វើឲ្យប្រព្រឹត្ត **សព្វបាបស្ស** នូវអំពើអាក្រក់ អំពើថ្គាំថ្គង ពិរុទ្ធភាព បទល្មើស បទឧក្រិដ្ឋគ្រប់ថ្នាក់គ្រប់កម្រិតគ្រប់យ៉ាង១, **កុសលស្សូបសម្បទា** វីកិរិយាចូលទៅបំពេញ គឺជាកិរិយាចូលទៅធ្វើពីលើបន្ថែមនៃការមិនធ្វើអំពើអាក្រក់នោះទៀត នូវអំពើល្អ អំពើជាប្រយោជន៍ សេចក្តីសុខចម្រើននិងសន្តិភាព (គ្រប់

យ៉ាងតាំងពីថ្នាក់ទាបជម្មតា) ដរាបដល់ថ្នាក់អរហត្ត-មគ្គ ឬក៏ការញ៉ាំងកុសល ការរក្សាបាននូវទង្វើល្អ អំពើជាប្រយោជន៍ដែលកើតមានឡើង ឲ្យកាន់តែចម្រើនឡើងថែមទៀត១, **សចិត្តបរិយោទបនំ** កិរិយាសម្អាតកិរិយា ជុសខាត់កិរិយាជម្រះកិរិយាហ្វឹកហាត់កិរិយា ទូន្មានអប់រំឲ្យផូរផង់ឲ្យផុតចាកគំនិតឥស្សា គំនិតលោភៈ គំនិតព្រហ្មណៃនឈ្នានីស គំនិតអគតិនិងគំនិតបៀតបៀនគេជាដើម១ **ឯតំ ពុទ្ធានសាសនំ** ទាំងអស់នេះជាឱវាទានុសាសនី គឺជាពាក្យទូន្មានប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ គឺថាព្រះពុទ្ធគ្រប់ព្រះអង្គសុទ្ធតែត្រាស់យ៉ាងនេះដូចគ្នាទាំងអស់ ។

ខន្តី បរមំ តបោ តីតិក្ខា
និព្វានំ បរមំ វទន្តិ ពុទ្ធា
ន ហិ បព្វជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ ។

(សម្រាយសេចក្តីគាថាទី២៧) **ខន្តី** រីអំណត់ធន់ គឺកិរិយាសង្កត់សង្កិន នូវចិត្តដែលខ្ញិលច្រអូសកោងកាចសាហាវយង់ឃ្នងវាត់ចេញ ពីការខំព្យាយាម **តីតិក្ខា** ជាការអត់ទ្រាំជាអំណត់ធ្មត់ជាការអត់ធន់ក្នុងការធ្វើរជាប្រយោជន៍ទាំងឡាយ **តបោ** ជាតបៈ គឺការប្រព្រឹត្តកម្ចាត់បង់ជាយន្តការ ជាមធ្យោបាយលុបបំបាត់ នូវបាបដែលជាអំពើអាក្រក់គ្រប់យ៉ាង **បរមំ** ដ៏ប្រសើរខ្ពង់ខ្ពស់បំផុត (គឺខន្តិបទការអត់ធន់នេះឯង), **ពុទ្ធា** រីពុទ្ធបុគ្គលទាំងឡាយ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះអនុពុទ្ធ **វទន្តិ** តែងត្រាស់សម្តែងថ្លែងពន្យល់ **និព្វានំ** នូវព្រះនិព្វានគឺសភាវៈជាសន្តិភាព ញ៉ាំងសត្វគ្រប់ជំពូកឲ្យរលាស់ខ្លួនចាកទុក្ខទោសកង្វល់អំពល់ក្នុងលោកទាំងបីបាន **បរមំ** ថាជាគុណជាតដ៏ឧត្តម ក្រៃលែងបំផុត គឺថាគ្មានសន្តិភាពណាជាងព្រះនិព្វានទៀតទេ, **ហិ** ជាការពិត

ណាស់ **បរូបឃាតី** វីបុគ្គល (ដែលចេញចាកផ្ទះ ហើយចូលមកកាន់បវរមណ្ឌលព្រះពុទ្ធសាសនា នៃព្រះជិនស្រីដែលប្ដេជ្ញាចិត្តថាគោរពព្រះធម្មវិន័យ ពុំនោះបុគ្គលដែលជាពុទ្ធសាសនិក ដែលប្រកាន់ជឿតាមព្រះពុទ្ធោវាទ) ជាអ្នកសម្លាប់កាប់ប្ញូន់បៀតបៀនបុគ្គលដទៃឲ្យវេទុក្ខគ្រោះថ្នាក់ជីវិត **បរំ វិហេឋយន្តោ** ឬក៏កាលសង្កត់សង្កិនជិះជាន់ ឈ្លានពាន ទន្ទ្រានធ្វើទុក្ខបុកម្នេញ បង្ខិនបង្ខំចប្រយោជន៍ប្រទូសរ៉ាយនូវបុគ្គលណាមួយដទៃ ដោយគ្រឿងប្រហារផ្សេងៗ មានបាតដៃជាដើម **ន បព្វជិតោ សមណោ ហោតិ** មិនសក្តិសម គឺថាមិនមែនជាបព្វជិត នៃពុទ្ធសាសនាដែលគេចចេញចាកផ្ទះ ឬត្រកូលប្ដេជ្ញាប្រព្រឹត្តធម្មវិន័យដើម្បីវៀរចាកបាបទេ មិនឈ្មោះថាជាសមណៈធ្វើតបៈរំងាប់បន្សាត់បង់នូវបាបអំពើអាក្រក់ទេ ។

អក្ខុបវាទោ អនូបឃាតោ ចាតិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ

អជិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ ។

(សម្រាយសេចក្ដីគាថាទី៣) **អនូបវាទោ ច** វីកិរិយាមិនតិះដៀលពោលមួលបង្កាច់ ពោលបង្ខូច ពោលអុជអាលញុះញង់ បំបែកបំបាក់ដោយខ្លួនឯងផ្ទាល់ ឬប្រើបញ្ជាអ្នកដទៃឲ្យតិះ ដៀលពោលបង្កាច់បង្ខូច១, **អនូបឃាតោ ច** វីកិរិយាមិនបៀតបៀនសម្លាប់ជាន់ឈ្លីញាំញី ដោយខ្លួនឯងផ្ទាល់ ឬប្រើបញ្ជាអ្នកដទៃឲ្យបៀតបៀន កាប់សម្លាប់ជាន់ឈ្លីញាំញី១, **បាតិមោក្ខេ សំវរោ ច** វីការសង្រួមការរវាំងការប្រុងប្រយ័ត្ន ដោយមិនប្រមាទក្នុងបាតិមោក្ខ គឺគុណជាតរំដោះសត្វឲ្យរួច ចាកទុក្ខនិងឥន្ទ្រិយសំវរ-សីល គឺការសង្រួមក្នុងសការៈជាធំមានក្អែកជាដើមឲ្យតាំងនៅជាធម្មតា ឬជាបុគ្គលគោរពប្រណិបតន៍ក្នុងច្បាប់សាសនា ច្បាប់សង្គមលោកទាំងជាតិ ទាំងអន្តរជាតិ ឬក៏គោរពសិទ្ធិសេរីភាពនៃជីវិតមនុស្សសត្វទូទៅ១, **មត្តញ្ញុតា ច** ការៈនៃបុគ្គលដឹង

ប្រមាណ គឺការព្រមល្មមក្នុងអាហារម្ហូបចំណីពុំនោះ ការចេះផ្អែតផ្អន់ ក្នុងធនធានទ្រព្យសម្បត្តិយសសក្តិ ដែលខ្លួនមាន មិនទៅលួចប្លន់បន្លំកិបកេងប្រវ័ញ្ច ដណ្ដើមយកពីអ្នកផ្សេងទៀតឡើយ គឺចេះព្រមល្មម ក្នុងការរស់នៅ១, **បន្តំ សយនាសនំ ច** ទីដេក ទីសំណាក់ និងទីអង្គុយដ៏ស្ងប់ស្ងាត់ គឺមិនមានការ រំខានពីអ្វីមួយ ដល់ការចម្រើនសមាធិចិត្ត និង វិបស្សនា ឬសម្រាប់បច្ចុប្បន្ននេះ បានដល់ប្រទេស ដែលមិនមានការគំរាមកំហែងពីសត្វសាហាវ ពី បរិយាកាស ពីបច្ចាមិត្ត ពីសស្ត្រាវុធ និងពីគ្រោះ ធម្មជាតិជាដើម១, **អធិចិត្តេ អាយោគោ ច** ការប្រឹង ប្រែងព្យាយាមដុសខាត់សម្អាត ក្នុងអធិចិត្ត គឺចិត្ត ដ៏ខ្ពង់ខ្ពស់ក្រៃលែង បានដល់ចិត្តដែលប្រកបដោយ សមាបត្តិ៨ ឬករណីក្នុងសង្គមលោកបច្ចុប្បន្ន គឺការ ព្យាយាមប្រឹងប្រែងហាមចិត្តដែលអគតិចិត្តច្រណែន

ឈ្នាទីស ចិត្តលោកៈមិនងោករេទៅតាមអំណាច បុណ្យសក្តិទឹកប្រាក់ឃ្វាតចាកយុត្តិធម៌ជាដើម១ **ឯតំ ពុទ្ធាន សាសនំ** ទាំងអស់នេះជា ឱវាទានុសាសនី គឺជាពាក្យទូន្មានប្រៀនប្រដៅ នៃព្រះពុទ្ធទាំងឡាយ គឺថាព្រះពុទ្ធគ្រប់ព្រះអង្គសុទ្ធតែត្រាស់យ៉ាងនេះដូចគ្នាទាំងអស់ ។

ក្រោយពីទ្រង់សម្តែង ឱវាទប្បាតិមោក្ខចប់ ព្រះពុទ្ធជាម្ចាស់ ទ្រង់ប្រកាសតែងតាំងព្រះភិក្ខុ២អង្គ ជាអគ្គសាវ័កស្តាំឆ្វេង ក្នុងព្រះពុទ្ធសាសនា គឺព្រះ-សារីបុត្រជាអគ្គសាវ័កស្តាំថា មហាបញ្ញានំ យទិទំ សារីបុត្តោ បណ្តាភិក្ខុទាំងឡាយដែលមានបញ្ញាច្រើនគឺស្រេចតែនឹងសារីបុត្ត, ឥទ្ធិមន្តានំ យទិទំ មហាមោគ្គល្លានោ បណ្តាភិក្ខុទាំងឡាយដែលមានឫទ្ធិច្រើនគឺស្រេចនឹងមហាមោគ្គល្លាន ។

# ព្រឹត្តិការណ៍ទី៣ គ.ទ្រង់ដាក់អាយុសង្ខារ



លំដាប់នោះ ព្រះមានព្រះភាគទ្រង់ប្រដាប់ត្រៃចីវរនិងបាត្រក្នុងបុព្វណ្ហសម័យ យាងចូលក្នុងក្រុងវេសាលី ដើម្បីបិណ្ឌបាតដោយមានព្រះអានន្ទជាបច្ឆាសមណៈ ។ លុះវេលាថ្ងៃ ទ្រង់យាងទៅកាន់បាវាលចេតិយ ហើយទ្រង់គង់លើអាសនៈដែលព្រះ-អានន្ទក្រាលថ្វាយ ។ ចំណែកព្រះអានន្ទក្រាលថ្វាយព្រះមានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ ។

លំដាប់នោះ ព្រះសាស្តាទ្រង់ត្រាស់សរសើរនូវទីក្រុងវេសាលី ជាក្រុងគួររីករាយ គួរត្រេកអរមានភោគផលច្រើន មានមនុស្សម្នាកុះករ មានឧទេន-

ចេតិយ និងបាវាលចេតិយជាដើមគួរជ្រះថ្លាទ្រង់បាន ថែមទាំងធ្វើនូវនិមិត្តនៃទីឋានទាំង១៦ កន្លែងរួមមាន ទៀបក្រុងរាជគ្រឹះ១០ គឺ ភ្នំគិជ្ឈកូដ, គោតមនិគ្រោធ, ភ្នំចោរប្បបាត, សត្តបណ្ណិគុហាខាងវេភារៈ, កាឡសិលាខាងឥសិគិលិ,ព្រៃសីតវ័ន, តបោទារាម, កលន្ទកនិវាបស្ថាន, ជីវកម្ពវ័ន, មទ្ទកុច្ឆិមិគទាយវ័ន និងទៀបក្រុងវេសាលី៦ ឧទេនចេតិយ, គោតមកចេតិយ, សត្តម្ពចេតិយ, ពហុ-បុត្តចេតិយ, សារន្ទទ-ចេតិយនិងបាវាលចេតិយ ។ ជាពិសេសទៅទៀត នោះ គឺទ្រង់ត្រាស់សម្តែងជាអនេកបរិយាយអំពីឥទ្ធិបាទធម៌មាន ៤ន្ទៈ វិរិយៈ ចិត្តៈនិងវីមំសា ដែលបុគ្គលណាមួយបានចម្រើនហើយ បានធ្វើរឿយៗ ហើយ ធ្វើឲ្យដូចយានហើយ បានធ្វើឲ្យជាទីនៅ ហើយ បានតាំងទុករឿយៗហើយ បានសន្សំទុក ហើយ បានប្រារព្ធដោយល្អហើយ បើប្រាថ្នានឹងឋិត

ថ្វាយបង្គំអារាធនាព្រះអង្គ ចូលនិព្វានភ្លាមតែម្តង ដោយអាងលេសហេតុថាសាវ័ក សាវិកា ឧបាសក ឧបាសិការបស់ព្រះអង្គ ដែលជាអ្នកចេះចាំព្រះធម៌ ព្រះវិន័យ អាចបង្ហាត់បង្រៀនបាននោះមានសព្វគ្រប់ហើយ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់តបនឹងមារមានចិត្តបាបវិញ "ម្នាលមារមានចិត្តបាប ចូរមានសេចក្តីខ្វល់ខ្វាយតិចចុះ, ការបរិនិព្វានរបស់តថាគតមិនយូរប៉ុន្មានទេ, កន្លងទៅតែ៣ខែទៀត អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ" ។ ខណៈនោះឯងមហាប្រឹថពី ក៏រម្ញើកញាប់ញ័រ គួរឲ្យព្រឺរោម គួរឲ្យភ្ញាក់ភ្ញើកគួរឲ្យរន្ធត់ស្ញប់ស្ញែង ។

ព្រះមានព្រះភាគ ទ្រង់ប្រកាសដាក់ជន្មាយុសង្ខារ នៅចំពោះមុខមារ ឰដ៏បាវាលចេតិយប្រកបសតិសម្បជញ្ញៈ ។ ព្រះអានន្ទ មានវិប្បដិសារីស្តាយក្រោយជាខ្លាំង ដោយដឹងហេតុនេះជាខាងក្រោយ

នៅអស់មួយអាយុកប្ប (ដែលជាអាយុកាលរបស់សត្វ ដែលរស់នៅក្នុងសម័យនេះ) ឬលើសជាងមួយអាយុកប្បក៏បាន,ឯឥទ្ធិបាទធម៌ទាំង៤នេះ គឺតថាគតខ្លួនឯងបានធ្វើឲ្យល្អប្រពៃហើយ ។ ទ្រង់សម្តែងយ៉ាងនេះ ក្នុងពុទ្ធបំណងដើម្បីរំឭកដាស់សតិព្រះអានន្ទអារាធនាព្រះជន្មនៅជាបន្តទៀត ។ តែព្រះអានន្ទដោយអំណាចមារចូលមកជ្រៀតជ្រែកចិត្ត ពុំអាចនឹកឃើញបានឡើយ ។ ព្រះពុទ្ធអង្គ ទ្រង់ព្យាយាមសម្តែងជាឱឡារិក ក៏នៅតែព្រះអានន្ទនឹករឭកមិនឃើញ ។ ដោយទតឃើញដូច្នេះ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ឲ្យព្រះអានន្ទចេញមកខាងក្រៅ ដែលជាឱកាសបានមារចូលមកគាល់ព្រះអង្គវិញ ។ មារាធិរាជ ដែលជាស្តេចតាមសម្លាប់នូវកុសលបុណ្យរបស់សត្វ ដែលបំពេញជានិច្ចកាលនោះ ហើយដែលធ្លាប់តែទើសចិត្តថ្នើមទើសមុខមាត់ខ្លួនយូរមកហើយនោះ

ហើយមិនអាចអារាធនាព្រះតថាគត គង់ព្រះជន្មនៅអស់អាយុកប្បបាន ។ គ្រានោះ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ព្រះគាថា ៖

ព្រះពុទ្ធ ជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញនូវព្រះនិព្វានដែលមានគុណាថ្លឹងមិនបានផង នូវភពផងទ្រង់លះបង់នូវសង្ខារ ដែលនាំសត្វទៅកាន់ភពផងទ្រង់ត្រេកអរនូវអារម្មណ៍ខាងក្នុង (ដោយអំណាចវិបស្សនា) មានព្រះហឫទ័យតាំងនៅហើយ (ដោយអំណាចសមថៈផង)ទ្រង់ទម្លាយនូវបណ្ដាញ គឺកិលេសដែលកើតមាននៅខាងក្នុងខ្លួនដូចជាគ្រោះ ។

ព្រោះព្រឹត្តិការណ៍ទាំង៣ ដូចបានពណ៌នាលើកឡើងមកនេះ ទើបពុទ្ធសាសនិកគ្រប់ស្រទាប់វណ្ណៈគ្រប់ត្រកូលគ្រប់ឋានានុក្រម ក្នុងដែនកម្ពុជរដ្ឋនាំគ្នាប្រារព្ធនូវបុណ្យមាឃបូជានេះ យ៉ាងឱឡារិក

ហើយធ្លាក់បានជាវប្បធម៌ អារ្យធម៌របស់ជាតិគ្រប់ជំនាន់គ្រប់សម័យកាល ។

ជាចុងបញ្ចប់នេះ សូមថ្ងៃអភិលក្ខិតសម័យនៃទិវាមាឃបូជា ជាបុណ្យពុទ្ធសាសនាដ៏ប្រកបដោយមហាបុញ្ញានុកូលភាព ប្រព្រឹត្តទៅជាកុសលប្រយោជន៍ ចំពោះមហាពុទ្ធសាសនិកទាំងឡាយនៅលើផ្ទៃភពនៃពិភពលោក និងពពួក ទេពនិករអមរមេឃ មារ ឥន្ទ្រ ព្រហ្ម ក្នុងចក្រវាឡទាំងអស់ឲ្យបាននូវសេចក្ដីសុខ សេចក្ដីចម្រើន និងសិរីមង្គលសុភផលបវរសួស្ដីគ្រប់ៗគ្នា កុំបីមានការឃ្លាតក្លាយទៅជាបការៈដទៃអស់កាលជាអង្វែងទៅហោង!!!

រៀបរៀងដោយ

**ឧបាសកាចារ្យ លី ប៊ុនលីន**

# លោកគ្រូព្រះមហាធម្មាលង្ការោ ចាន់ សុជន
# ប្រធានកម្មវិធីធាធីសំឡេងព្រះធម៌
# វត្តប្រាសាទស្រះកណ្ដាល(ខ្ចាស់)

បានពិនិត្យ និងឯកភាព

ធ្វើនៅវត្តប្រាសាទស្រះកណ្ដាល(ខ្ចាស់)
ថ្ងៃ១៥កើត ខែមាឃ ព.ស.២៥៥៨
ត្រូវនឹងថ្ងៃអង្គារ ទី៣ ខែកុម្ភៈ ឆ្នាំ២០១៥